ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា
លេខ: ១៤៦៤ ន.ទ.ក.

# សេចក្តីណែនាំ
# ស្តីពី
# ការស្នើសុំលិខិតអនុញ្ញាតការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតនៅក្នុងរាជធានីភ្នំពេញ

និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ អនុលោមតាមច្បាប់ស្តីពីទូរគមនាគមន៍ បុគ្គលទាំងឡាយជាជនជាតិខ្មែរ ឬ ជនជាតិបរទេស ដែលចង់បំពេញប្រតិបត្តិការទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានកំណត់នៅក្នុងចំណុច "ខ" មាត្រា ១៥ នៃច្បាប់នេះ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតពី ន.ទ.ក. ។ ដូច្នេះ ដើម្បីបង្កើនភាពងាយស្រួលដល់អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ន.ទ.ក. សូមធ្វើការណែនាំអំពីនីតិវិធី និង ឯកសារតម្រូវដូចខាងក្រោម៖

## ក. សេវា

- លិខិតអនុញ្ញាតការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត

## ខ. ស្ថាប័នផ្តល់សេវា

និយ័តករទូរគមនាគមន៍កម្ពុជា៖

ក្នុងករណីដាក់ពាក្យដោយផ្ទាល់៖

- បញ្ជរអតិថិជន (ផ្នែកប្រឹក្សាព័ត៌មាន ទទួលពាក្យ បង់ប្រាក់ និងទទួលលិខិតអនុញ្ញាត)
- អាសយដ្ឋាន៖ អគារ ន.ទ.ក. វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
  - ទូរស័ព្ទ៖ ១២៧២ ឬ ០២៣ ៧២ ២៣ ៣៣
  - ទូរសារ៖ ០២៣ ៧២ ៣២ ២២
  - អ៊ីម៉ែល៖ frontdesk@trc.gov.kh

ក្នុងករណីដាក់ពាក្យដោយប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម៖

- គេហទំព័រ៖ www.trc.gov.kh/online

## គ. គោលបំណងនៃការផ្តល់សេវា

បង្កើនភាពងាយស្រួលដល់សាធារណជនក្នុងការស្នើសុំលិខិតអនុញ្ញាត ដើម្បីបំពេញប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍នៅក្នុងប្រទេសកម្ពុជា ព្រមទាំងធានាគុណភាពសេវា និងការគ្រប់គ្រងប្រព័ន្ធអ៊ិនធឺណិតឱ្យមានប្រសិទ្ធភាពស្របតាមបទដ្ឋានអន្តរជាតិ និងបើកទូលាយសេវាបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានជូនដល់ប្រជាពលរដ្ឋ។

## ឃ. មូលដ្ឋានគតិយុត្ត

- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- ប្រកាសលេខ ១៥៥ ប.ទ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការគ្រប់គ្រងប្រព័ន្ធ និងសេវាអ៊ិនធឺណិត និងប្រភេទសេវា VoIP នៅព្រះរាជាណាចក្រកម្ពុជា
- សារាចរអន្តរក្រសួងលេខ ០០១ សរ.មផ-បទ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្ម និងការប្រើប្រាស់សេវាកម្មទូរគមនាគមន៍


វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

- ប្រកាសលេខ ១៧៩ ប.ទ.ប្រក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីអាជ្ញាបណ្ណបើកអាជីវកម្មសាលបម្រើអ៊ិនធឺណិត
- ប្រកាសលេខ ១២២ បទ.ប្រក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការកែប្រែ ការព្យួរ ការផ្ទេរ និង ការដកហូត លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬ អាជ្ញាបណ្ណប្រតិបត្តិការទូរគមនាគមន៍
- ប្រកាសរួមលេខ៤៩៩ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់និយ័តករទូរគមនាគមន៍កម្ពុជា ។

## ខ. អតិថិជនដែលមានសិទ្ធិទទួលសេវា

ជនជាតិខ្មែរ ឬ ជនបរទេស ជារូបវន្តបុគ្គល ឬ នីតិបុគ្គល។

## ច. ស្តង់ដាសេវា

### ១. រយៈពេលផ្តល់សេវា

- ១០ ថ្ងៃ (ថ្ងៃធ្វើការ) សម្រាប់ការពិនិត្យ វាយតម្លៃ និងសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត បន្ទាប់ពីអ្នកស្នើសុំបានបំពេញពាក្យស្នើសុំត្រឹមត្រូវ និងផ្តល់ឯកសារគ្រប់គ្រាន់។

### ២. កម្រៃ

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតត្រូវបង់៖

- កម្រៃទទួល និងពិនិត្យពាក្យស្នើសុំបើកថ្មី ឬប្តូរទីតាំង ចំនួន ២០.០០០ (ម្ភៃពាន់) រៀល ។
- កម្រៃទទួល និងពិនិត្យពាក្យសុំបន្តសុពលភាព ពុំគិតថ្លៃ ។
- កម្រៃលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម (១ឆ្នាំ) ចំនួន ១០០.០០០ (មួយរយពាន់) រៀល។

ចំពោះការផ្តល់លិខិតអនុញ្ញាតសម្រាប់ឆ្នាំដំបូង ការយកកម្រៃសេវាត្រូវគិតតាមរយៈពេលនៅសល់ក្នុងឆ្នាំ យោងតាមកាលបរិច្ឆេទចុះហត្ថលេខាលើលិខិតអនុញ្ញាតរបស់ ន.ទ.ក. ដូចខាងក្រោម ៖

- រយៈពេលនៅសល់មិនលើស ៦ខែ ត្រូវគិតកម្រៃ ៥០% (ហាសិបភាគរយ) នៃកម្រៃប្រចាំឆ្នាំ
- រយៈពេលនៅសល់លើសពី ៦ខែ ត្រូវគិតកម្រៃពេញមួយឆ្នាំនៃកម្រៃប្រចាំឆ្នាំ។

## ឆ. ឯកសារតម្រូវដើម្បីទទួលបានសេវា

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត ត្រូវបំពេញពាក្យសុំដូចមានគំរូនៅក្នុងឧបសម្ព័ន្ធទី១ និង ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬ សៀវភៅគ្រួសារ ឬ លិខិតឆ្លងដែនមានសុពលភាព..០១ ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកអាជីវកម្ម និង កិច្ចសន្យាជួលទីតាំងបើកអាជីវកម្ម មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង).....០១ ច្បាប់

ក្នុងករណីអ្នកស្នើសុំដែលបានទទួលលិខិតអនុញ្ញាតបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត មានបំណងចង់ផ្លាស់ប្តូរអាសយដ្ឋានសាល ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី២ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតចាស់........................................ ០១ ច្បាប់
- លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ទីតាំងបើកអាជីវកម្ម និង កិច្ចសន្យាជួលទីតាំងបើកអាជីវកម្ម មានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន (ក្នុងករណីជួលទីតាំង).....០១ ច្បាប់

ក្នុងករណីអ្នកស្នើសុំមានបំណងចង់បន្តអាជីវកម្ម ឬបន្តលិខិតអនុញ្ញាត ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី៣ ឱ្យបានមុន ៣០ (សាមសិប) ថ្ងៃមុនលិខិតអនុញ្ញាតអស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិតចាស់........................................ ០១ ច្បាប់

ក្នុងករណីអ្នកស្នើសុំមានបំណងចង់បញ្ឈប់អាជីវកម្ម ឬលុបលិខិតអនុញ្ញាត ត្រូវដាក់ពាក្យសុំដូចមានគំរូក្នុងឧបសម្ព័ន្ធទី៤ ឱ្យបានមុន ៣០ (សាមសិប) មុនលិខិតអនុញ្ញាតអស់សុពលភាព និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត................................................០១ ច្បាប់
- ច្បាប់ចម្លងបង្កាន់ដៃបង់ប្រាក់.............................................................................០១ច្បាប់

ក្នុងករណីផ្លាស់ប្តូរនាមករណ៍ម្ចាស់ ឬសាលបម្រើអ៊ិនធឺណិត អ្នកស្នើសុំត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតថ្មី ។

## ៥. លក្ខខណ្ឌ

អ្នកទទួលលិខិតអនុញ្ញាតត្រូវអនុវត្តដូចតទៅ៖

១. ត្រូវគោរពឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិដូចមានចែងក្នុងចំណុច (ឃ) និង លិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន។

២. ត្រូវអនុវត្តស្របតាមលិខិតអនុញ្ញាត និង មិនត្រូវប្រើប្រាស់សាលបម្រើសេវាអ៊ិនធឺណិត ជាទីតាំងសម្រាប់បង្កផលប៉ះពាល់ដល់សន្តិសុខជាតិដែលត្រូវហាមឃាត់ដោយដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា។

៣. ហាមមិនឱ្យធ្វើអាជីវកម្មហ្គេម (Game) ដែលមានលក្ខណៈជាល្បែងស៊ីសង និងប្រើប្រាស់គេហទំព័រអាសអាភាសនៅតាមសាលបម្រើសេវាអ៊ិនណិតរបស់ខ្លួន ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសេចក្តីថ្លៃថ្នូររបស់សង្គមជាតិដែលត្រូវហាមឃាត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានានៃព្រះរាជាណាចក្រកម្ពុជា។

៤. រាល់ការផ្ទេរ បន្ត ឬ បោះបង់ចោល(ឈប់ប្រតិបត្តិការ)លិខិតអនុញ្ញាត ត្រូវសុំការអនុញ្ញាតជាមុនពី ន.ទ.ក.។

៥. ករណីលិខិតអនុញ្ញាតផុតសុពលភាព ឬលិខិតអនុញ្ញាតមានសុពលភាពនៅសល់តិចជាង ៣០ (សាមសិប) ថ្ងៃ អ្នកស្នើសុំដែលមានបំណងបន្តអាជីវកម្មត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតថ្មី ។

៦. ករណីផ្លាស់ប្តូរអាសយដ្ឋានសាល សុពលភាពនៃលិខិតអនុញ្ញាតថ្មីត្រូវគិតតាមសុពលភាពនៃលិខិតអនុញ្ញាតដែលបានផ្តល់ជូនសម្រាប់ទីតាំងសាលចាស់ ។

៧. ត្រូវចូលរួមអនុវត្តតាមការណែនាំរបស់មន្ត្រីត្រួតពិនិត្យនៃ ន.ទ.ក.។

៨. ក្នុងករណីអនុវត្តផ្ទុយពីសេចក្តីណែនាំនេះ អ្នកទទួលលិខិតអនុញ្ញាត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ថ្ងៃទី ព្រហស្បតិ៍ ៣កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០១៨

**ប្រធាន**

TELECOMMUNICATION REGULATOR OF CAMBODIA

**ស៊ា ណារ៉េត**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
-និយ័តករទូរគមនាគមន៍កម្ពុជា
"ដើម្បីអនុវត្ត"
-ឯកសារ -កាលប្បវត្តិ